| | |
|---|---|
| តុលាការកំពូល<br>សភាព្រហ្មទណ្ឌ<br>សំណុំរឿងព្រហ្មទណ្ឌ<br>លេខៈ ២៦<br>ចុះថ្ងៃទី១៧-០៥-៩៩<br>សាលដីកាលេខ៖ ២៣<br>ចុះថ្ងៃទី១៨-០៨-៩៩ | ព្រះរាជាណាចក្រកម្ពុជា<br>ជាតិ សាសនា ព្រះមហាក្សត្រ<br>តាងនាមប្រជារាស្ត្រខ្មែរ<br>តុលាការកំពូល |

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១-ឯកឧត្តម... ប្រធាន

២-លោក... ចៅក្រម

៣-លោក... ចៅក្រម

៤-លោក... ចៅក្រមរបាយការណ៍

៥-លោក... ចៅក្រម

ក្រឡាបញ្ជី

លោក...

តំណាងមហាអយ្យការ

លោក...ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្ដឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៩១ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៤៩ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២៦ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការកំពូល។

***ពីបទៈ*** មនុស្សឃាតដោយចេតនាប្រព្រឹត្ត នៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

-ជនជាប់ចោទឈ្មោះ **ឈឈ** (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ របររកស៊ីនគរបាលនៅក្រសួងមហាផ្ទៃ ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ២៥១ ផ្លូវឧកញ៉ាទេពផន ក្រុមទី២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ **ពច** ម្តាយឈ្មោះ **អអ** ប្រពន្ធឈ្មោះ **វជឡ** មានកូន១នាក់។ក្នុងឃុំ។

មានមេធាវី...

-ដើមបណ្តឹងរដ្ឋប្បវេណី និងជាប្តីជនរងគ្រោះឈ្មោះ **យយណ** (ជាចុងបណ្តឹងសាទុក្ខ) អាយុ៤៩ឆ្នាំ ជាតិខ្មែរ របររកស៊ីមន្ត្រីក្រសួងអប់រំ ទីលំនៅសព្វថ្ងៃផ្ទះលេខ៧២ ផ្លូវលេខ៤៨៤ ក្រុមទី៥១ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក ក្រុងភ្នំពេញ។

-តាមបណ្តឹងសាទុក្ខលេខ៣៨ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ របស់លោក...ជាមេធាវីការពារឱ្យជនជាប់ចោទ ឈ្មោះ **ឈឈ** ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៩១ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល។

-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៣-២-៩៩ របស់ឈ្មោះ **យយណ** ភេទស្រី និងបក្សពួក៤នាក់ទៀតធ្វើសកម្មភាពមនុស្សឃាតមកលើគ្រួសារខ្លួនប្រពន្ធ និងក្មួយស្រី២នាក់ទៀត ត្រូវស្លាប់ដោយកាំបិតអារក និងចងក ព្រមទាំងដាក់ខ្នោះ។

-បានឃើញដីកាឃុំខ្លួនលេខ១៥២ ចុះថ្ងៃទី០២ខែមីនា ឆ្នាំ១៩៩៩ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ។

-បានឃើញដីកាសម្រេចលេខ១៥០២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញដែលបានសម្រេច។

១-ទទួលពាក្យ បណ្ដឹងសុំនៅ ក្រៅឃុំជាបណ្ដោះអាសន្ន របស់ឈ្មោះ **ឈឈ** ដោយមានមេធាវីឈ្មោះ ... ចុះថ្ងៃទី០២-០៤-៩៩ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់។

២-បន្តការឃុំខ្លួនឈ្មោះ **ឈឈ** ជាបណ្ដោះអាសន្នតទៅទៀត។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៩(គ) ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩ របស់លោក...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **ឈឈ** ដែលប្ដឹងតវ៉ាពីដីកាសម្រេចលេខ១៥០២ ព្រ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើដីកាសម្រេចទាំងមូល។

-បានឃើញសេចក្ដីសន្និដ្ឋាន នាពេលសវនាការ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ ក្នុងដំណាក់កាលបច្ចុប្បន្ន គឺជាដំណាក់កាលប្រមូលភស្ដុតាង ការសុំនៅក្រៅឃុំនេះពុំមែនជាដំណាក់កាល ឱ្យឈ្មោះ**ឈឈ** នៅក្រៅឃុំនោះទេ តំណាងមហាអយ្យការពុំអនុញ្ញាត ឱ្យនៅក្រៅឃុំឡើយ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ៩១ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦-០៤-៩៩ របស់ឈ្មោះ... មេធាវីការពារជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់ដីកាសម្រេចលេខ១៥០២តព្រ ចុះថ្ងៃទី០៦-០៤-៩៩ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់។

-ឃើញបណ្តឹងសាទុក្ខលេខ៣៨ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ របស់លោក...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **ឈឈ** ដែលប្តឹងពីសាលដីកាព្រហ្មទណ្ឌលេខ៩១ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ របស់ឈ្មោះ **ឈឈ** (ជាម្ចាស់បណ្តឹងសាទុក្ខ)ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានឃើញសារណាតប ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨៩ របស់ឈ្មោះ **ឃឃណ** (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖

១-បណ្តឹងសាទុក្ខរបស់លោក...ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើករឿងនេះមកពិនិត្យពិចារណា។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៩១ ចុះថ្ងៃទី២៣-០៤-៩៩របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-បានស្តាប់ចម្លើយអះអាង របស់ជនជាប់ចោទឈ្មោះ **ឈឈ** (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា៖សូមឱ្យតុលាការដោះលែងព្រោះខ្ញុំបាទមានជំងឺ ពុំជាប់សាច់ញាតិជាមួយជនរងគ្រោះទេ ហើយពុំដែលស្គាល់ដែរ។ នៅ

ថ្ងៃកើតហេតុខ្ញុំនៅកន្លែងធ្វើការ និង នៅផ្ទះរហូតលុះល្ងាចក្រោយពី ខ្ញុំបាទត្រឡប់មកពីមន្ទីរពេទ្យមើលជនរងគ្រោះ ស្រាប់តែបេអឹមចាប់ខ្លួនខ្ញុំបាទតែម្តង។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាប្តីជនរងគ្រោះឈ្មោះ **យយណ** (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា៖ លោក **ឈឈ** ឆ្លើយថាខ្លួនពុំជាប់សាច់ញាតិជាមួយជនរងគ្រោះគឺជាការឆ្លើយខុសក្នុងសារណា បើចង់រកយុត្តិធម៌ឱ្យលោក **ឈឈ** ទាល់តែសួររកចម្លើយ ***វវ*** ព្រោះតាមរបាយការណ៍ ប៉េអឹមបញ្ជាក់ថា **ផសណ** ជាអ្នកយក ***វវ*** ទៅផ្ញើផ្ទះបងប្អូននៅស្រែអំបិល ខេត្តកោះកុង។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក.......ជាមេធាវីការពារឱ្យជនជាប់ចោទ ឈ្មោះ **ឈឈ** (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា៖ ការចាប់ខ្លួនកូនក្តីខ្លួនក្នុងការសង្ស័យគ្មានភស្តុតាងពុំមែនជាបទល្មើសជាក់ស្តែង ម្យ៉ាងទៀតកូនក្តីខ្លួនជាមន្ត្រីរាជការ ការចាប់ខ្លួនត្រូវសុំការអនុញ្ញាតពីសាមីក្រសួង។ចំពោះឃុំខ្លួនលើសរយៈពេលកំណត់ សូមតុលាការដោះលែង។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម នាពេលសវនាការរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ រឿងឃុំខ្លួនពុំមែនជារឿងអង្គសេចក្តីទេ សូមតុលាការសម្រេចតាមច្បាប់។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ។

- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

# តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៨ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៩៩ របស់លោក...មេធាវីការពារជនជាប់ចោទឈ្មោះ **ឈឈ** ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថាការលើកឡើង របស់ជនជាប់ចោទឈ្មោះ **ឈឈ** ក្នុងសារណា ចុះថ្ងៃទី១៥-០៦-៩៩ ថា៖ ការយល់ឃើញ របស់សាលាឧទ្ធរណ៍ តាមកំណត់ហេតុចង្អុលបង្ហាញលើកទី១របស់អធិការដ្ឋានខណ្ឌទួលគោកថា ខ្លួនជាជនសង្ស័យ និងថាខ្លួននិងជនរងគ្រោះជាបងប្អូននឹងគ្នា ចុះហេតុអ្វីបានជានៅថ្ងៃ២៣-០២-៩៩ដែលជាថ្ងៃប្រព្រឹត្តិបទល្មើសនោះឈ្មោះ **សណជវ** មិនប្រាប់ឈ្មោះ **យយណ** ថាខ្លួនជាជនល្មើសនោះ ជាការពុំត្រឹមត្រូវឡើយពីព្រោះថា៖

-នៅចំពោះមុខនគរបាលខណ្ឌទួលគោក ជនជាប់ចោទ ឈ្មោះ **ឈឈ** បានឆ្លើយថាកន្លងមកខ្លួនពុំ ដែលស្គាល់ និងទំនាក់ទំនងជាមួយក្រុមគ្រួសារជនរងគ្រោះទេ ហើយតាំងពីខ្លួនរៀបការមកប្រពន្ធខ្លួនពុំដែលណែនាំខ្លួនឱ្យស្គាល់បងប្អូន ដែលជាក្រុមគ្រួសារជនរងគ្រោះទេ។

-ក្នុងកំណត់ហេតុចង្អុលបង្ហាញលើកទី១នៅអធិការដ្ឋានគរបាលខណ្ឌទួលគោក ជនរងគ្រោះ អ្នកស្រី **សណជវ** បានឆ្លើយថា រូបថតជនសង្ស័យឈ្មោះ **ឈឈ** ដែលសមត្ថកិច្ចបង្ហាញ គឺពិតជាជនល្មើស ដែលបានចូលរួមក្នុងសកម្មភាពឃាតកម្មនោះ ហើយចំពោះអាវុធប៉េអាកុលកូរ៉េ ដែលសមត្ថកិច្ចបង្ហាញខ្លួន គឺពិតជាអាវុធ ដែលពួកជនល្មើស ប្រើប្រាស់ក្នុងពេលធ្វើសកម្មភាពឃាតកម្មនេះ។

-នៅចំពោះមុខអយ្យការអមតុលាការក្រុងភ្នំពេញ ជនជាប់ចោទឈ្មោះ **ឈឈ** បានឆ្លើយថាចម្លើយរបស់ខ្លួន នៅនគរបាលខណ្ឌទួលគោកខ្លួនឥតកែប្រែទេ។

-យល់ឃើញថា បទល្មើសនេះជាបទឧក្រិដ្ឋ ហើយលទ្ធផលស៊ើបអង្កេតជាបឋម បានបង្ហាញនូវភស្តុតាងធន់ល្មម អាចឃុំខ្លួនជនជាប់ចោទជាបន្តទៅទៀតបាន។ ម្យ៉ាងទៀតបើសិនជា អនុញ្ញាតឱ្យជននេះនៅក្រៅឃុំជាបណ្ដោះអាសន្ន អាចបណ្ដាលឱ្យខូចដល់នីតិវិធីនៃការស៊ើបអង្កេតផងដែរ។

-យល់ឃើញថា ការលើកឡើងរបស់មេធាវីជនជាប់ចោទនាពេលសវនាការនេះថា ការចោទប្រកាន់ជនជាប់ចោទ ដោយពុំមានការសុំការអនុញ្ញាតជាមុនពីអង្គភាពសាម៉ីគឺជាការរំលោភទៅលើមាត្រា៥១ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថាការសុំអនុញ្ញាតឬការមិនសុំអនុញ្ញាតដល់អង្គភាពសាម៉ីពុំអាចប៉ះពាល់ដល់នីតិវិធី របស់តុលាការឡើយ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៩១ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ។

## ហេតុដូច្នេះ

វិនិច្ឆ័យ សេចក្ដីចំពោះ មុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី

១-ទទួលបណ្ដឹងសាទុក្ខលេខ៣៨ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ របស់លោក... ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៩១ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ២៦ ចុះថ្ងៃទី១៧-០៥-៩៩ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីអនុវត្តតាមនីតិវិធី។

៤-សាលដីកានេះ ប្រកាសសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩។